**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍**

**លេខ:០០២/០៧ របក.អគគ**

# របាយការណ៍

# ស្តីពី

# លទ្ធផលនៃការអនុវត្ត

# កម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ

# កំណែទម្រង់ច្បាប់ និងតុលាការ

# ឆមាសទី ១ ឆ្នាំ ២០០៦

រាជរដ្ឋាភិបាល បានអនុម័តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ដែលជាកាលបរិច្ឆេទបញ្ចប់ដំណាក់កាលទី១ គឺការរៀបចំចក្ខុវិស័យ យុទ្ធសាស្ត្រ និងកម្មវិធីសកម្មភាព និងចាប់ផ្តើមដំណាក់ទី២ គឺការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ។ នៅក្នុងដំណាក់ទី២នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ជាអ្នកសម្របសម្រួលដំណើរការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សា ជាមួយស្ថាប័នរដ្ឋ និងស្ថាប័នអន្តរជាតិនានាដែលពាក់ព័ន្ធ និងមានអង្គភាពគ្រប់គ្រងគម្រោងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ជាសេនាធិការ បានបំពេញការងាររបស់ខ្លួនយ៉ាងសកម្មក្នុងការផ្សព្វផ្សាយ និងទំនាក់ទំនង ក៏ដូចជាក្នុងការសម្របសម្រួល និងជំរុញការអនុវត្តកម្មវិធីសកម្មភាពអោយទទួលបានលទ្ធផលគួរជាទីមោទនៈ ។

## I-ការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

**ក-ការងារផ្សព្វផ្សាយ និងទំនាក់ទំនង**

- អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (អ.ស.អ) និងអង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ) បានរៀបចំការប្រជុំ និងធ្វើសិក្ខាសាលា ដើម្បីផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្ត យុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការ ដែលគណៈរដ្ឋមន្រ្តីបានអនុម័តក្នុងសម័យប្រជុំ ពេញអង្គ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ បានយ៉ាងទូលំ ទូលាយ ៖

  - ជូនក្រសួង ស្ថាប័នអ្នកអនុវត្ត នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥
  - ជូនសង្គមស៊ីវិល នៅថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៥
  - ជូនសហគមន៍ផ្តល់ជំនួយ នៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៥ ។

ឯកសារស្តីពីកម្មវិធីសកម្មភាពនេះ ក៏បានធ្វើការចែកជូនគ្រប់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលរួចរាល់អស់ ហើយដែរ។ ការផ្សព្វផ្សាយ ក៏បានអនុវត្តនៅតាមខេត្ត ក្រុងមួយចំនួនទៀត មានជាអាទិ៍ ខេត្តតាកែវ ខេត្តកំពត និងក្រុងកែប និងខេត្តកំពង់ស្ពឺ ក្នុងឆ្នាំ ២០០៥ និងក្រុងព្រះសីហនុ ខេត្តកោះកុង ខេត្តក្រចេះ ខេត្តសៀមរាប ខេត្ត បាត់ដំបង នៅដើមឆ្នាំ ២០០៦ នេះ ។

- កម្មវិធីសកម្មភាពខាងលើនេះ ក៏ត្រូវបានធ្វើការបញ្ចូលទៅក្នុងផែនការសកម្មភាព អភិបាលកិច្ចទី ២ (២០០៥-២០០៨) និងក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិ (២០០៦-២០១០) ផងដែរ ។
- បន្ថែមលើការងារផ្សព្វផ្សាយខាងលើ គណៈប្រតិភូកំណែទម្រង់ច្បាប់ និងតុលាការដឹកនាំដោយឯកឧត្តម ស៊ុំ ម៉ានិត ប្រធាន អ.ស.អ បានចុះធ្វើទំនាក់ទំនងផ្ទាល់ជាមួយក្រសួង ស្ថាប័នគន្លឹះមួយចំនួន ដើម្បីបញ្ជាក់ជូន អំពីការងារ និងភារកិច្ចពាក់ព័ន្ធរបស់ក្រសួង និងអំពីទំនាក់ទំនងការងារជាមួយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ រួមមាន: ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងមហាផ្ទៃ ក្រសួងពាណិជ្ជកម្ម និងក្រសួងយុត្តិធម៌ ព្រមទាំងបានស្នើសុំអោយក្រសួងទាំងនោះ ធ្វើការចាត់តាំងបង្កើតក្រុមការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធ យុត្តិធម៌ សម្រាប់ក្រសួងនីមួយៗផងដែរ ។
- ដោយឡែកក្រុមការងារបច្ចេកទេសចម្រុះ (TWG) កំណែទម្រង់ច្បាប់ និងតុលាការ ក៏បានប្រជុំ ពិនិត្យ តាមដានការអនុវត្ត សូចនាករណ៍រួមបានជាប្រចាំ រៀងរាល់ពីរខែម្តង និងទំនាក់ទំនងល្អជាមួយគណៈកម្មការ

សម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ (GDCC).

•ដើម្បីសម្រួលដល់ការងារចូលរួមពាក់ព័ន្ធរបស់សហគមន៍ផ្តល់ជំនួយ ក៏ដូចជាការងារពង្រឹងទំនាក់ទំនង រកដៃគូអភិវឌ្ឍន៍ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំជាបន្តនូវបញ្ជីគម្រោងមួយ (Project Catalogue) ដែលមានទាំងគម្រោងកំពុងអនុវត្ត ទាំងគម្រោងថ្មីចំនួនសរុប ៥៥គម្រោង សំរាប់ធ្វើការ ផ្សព្វផ្សាយនូវបញ្ជីនោះ ជូនសហគមន៍ផ្តល់ជំនួយ និងអ្នកពាក់ព័ន្ធ ។

## ខ.លទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់និងតុលាការ

•បន្ទាប់ពីអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (អ.ស.អ) និងអង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ) បានធ្វើ ទំនាក់ទំនងផ្ទាល់ជាមួយក្រសួងស្ថាប័ន ក្រុមការងារតាមក្រសួងស្ថាប័នគន្លឹះនីមួយៗដែលជាអ្នកដើរ តួនាទីដ៏សំខាន់ ក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ ត្រូវបានបង្កើត ៖

- ក្រសួងអប់រំយុវជន និងកីឡា (លិខិតឧទ្ទេសនាមលេខ ២៨២ អយក.ឧទន ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦)
- ក្រសួងយុត្តិធម៌ (សេចក្តីសម្រេចលេខ ០៣ កយសសរ០៦ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៦)
- ក្រសួងមហាផ្ទៃ (សេចក្តីសម្រេចលេខ ២០១ ស.ស.រ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៦)
- ក្រសួងពាណិជ្ជកម្ម (លិខិតចាត់តាំងលេខ ៩២៧/ំរៀជ/ព្រំ ២០០៦ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦)
- តុលាការកំពូល (សេចក្តីសម្រេចលេខ ២២៣/០៦ តកក.សសរ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦)

ក្រោយពីការបង្កើតក្រុមការងារនីមួយៗរួចមក ក្រុមការងារបានអនុវត្តភារកិច្ចរបស់ខ្លួន និងបានធ្វើរបាយការណ៍អំពីការងាររបស់ក្រសួងសំរាប់អនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ផ្ញើមកអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដូចមានជូនភ្ជាប់ជាឧបសម្ព័ន្ធ ។

•ក្នុងការងារទំនាក់ទំនងស្វែងរកជាបន្តនូវដៃគូអភិវឌ្ឍន៍ ក្រុមការងាររបស់ ក.ក.ច.ន.យ ដឹកនាំដោយ ឯកឧត្តម ស៊ុំ ម៉ានិត បានចុះទៅពិភាក្សាដោយផ្ទាល់ជាមួយ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ស្ថានទូត បារាំង ជប៉ុន កាណាដា សហរដ្ឋអាមេរិក អូស្ត្រាលី ដាណឺម៉ាក និងចក្រភពអង់គ្លេស ។ ដោយឡែក ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក៏បានទទួលជួបគណៈប្រតិភូសហភាពអឺរ៉ុប (EU) ផងដែរ។

ក្នុងការងារទំនាក់ទំនងរកដៃគូអភិវឌ្ឍន៍ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បាន សម្រេចជាលទ្ធផលដូចខាងក្រោម ៖

- បាន និងកំពុងបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍វិទ្យាស្ថានដាណឺម៉ាក ដើម្បីសិទ្ធិមនុស្ស (DIHR) ក្នុងការពង្រីកសមត្ថភាព អ.គ.គ ការរៀបចំសៀវភៅណែនាំសំរាប់វិស័យ (Sector Manual) ការរៀបចំប្រព័ន្ធតាមដាន (Indicator System).
- បានចុះហត្ថលេខាលើអនុស្សារណៈ នៃកិច្ចព្រមព្រៀងរវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធ យុត្តិធម៌ (ក.ក.ច.ន.យ) និងវិទ្យាស្ថានគ្រប់គ្រងបស្ចឹម-បូព៌ា (EWMI) នាថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ ដើម្បីធ្វើការស្ទង់មតិអំពីជំនួយផ្នែកច្បាប់ និងរៀបចំសិក្ខាសាលាអំពីក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជ អាជ្ញា ហើយបានឯកភាពលើលក្ខខ័ណ្ឌការងារយោង (ទ្រឡ) និងចុះធ្វើការស្ទង់មតិអំពីជំនួយផ្នែកច្បាប់តាមតំបន់ ខេត្ត ក្រុង ដែលបានកំណត់ដូចខាងក្រោម:

+ខេត្តក្រចេះ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៦ (ខេត្តមណ្ឌលគីរី និងខេត្តរតនៈគីរីចូលរួម)

+ខេត្តសៀមរាប ថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៦(ខេត្តឧត្តរមានជ័យចូលរួម)

+ក្រុងភ្នំពេញថ្ងៃទី២៥ខែមេសាឆ្នាំ២០០៦(ខេត្តកំពង់ចាម និងខេត្តស្វាយរៀងចូលរួម)

+ខេត្តបាត់ដំបង ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦(ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់ចូលរួម)

+ក្រុងព្រះសីហនុ ថ្ងៃទី១៩ ខែ ឧសភា ឆ្នាំ២០០៦(ខេត្តកំពត ក្រុងកែប និងខេត្តកោះកុងចូលរួម)

ដោយឡែកចំពោះក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា បានរៀបចំសិក្ខាសាលាចំនួនពីរលើក និងកំពុងពិនិត្យកែសំរួលជាចុងក្រោយនៅតុលាការកំពូល ។

- បានរៀបចំឯកសារសម្រាប់កិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងកម្មវិធីអភិវឌ្ឍន៍អង្គការសហ ប្រជាជាតិ (UNDP) ក្នុងការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា ដែលមានសកម្មភាពចំនួន ៤ សំរាប់អនុវត្ត ។ ឯកសារនេះត្រូវបាន ឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី និងជាសហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ចុះហត្ថលេខា នាថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦ ។

- សកម្មភាពទាំងបួនរួមមាន:

១-កម្មវិធីយល់ដឹងពីសិទ្ធិជាមូលដ្ឋាននៅកំរិតសហាគមន៍
(អនុវត្តដោយអង្គភាពគ្រប់គ្រង គម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌)

២-ការធ្វើអោយប្រសើរឡើងនូវចីរភាពនៃរាជកិច្ច និងទិន្នន័យច្បាប់
(អនុវត្តដោយទីស្តីការ គណៈរដ្ឋមន្ត្រី-អគ្គនាយកដ្ឋានរាជកិច្ច)

៣-ការបោះពុម្ព និងផ្សព្វផ្សាយសេចក្តីសម្រេចរបស់តុលាការ (អនុវត្តដោយតុលាការកំពូល)

៤-ការសិក្សាទាក់ទងនឹងដំណោះស្រាយវិវាទក្រៅតុលាការ និងកម្មវិធីសកម្មភាព
(អនុវត្ត ដោយក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ) ។

ដើម្បីអនុវត្តសកម្មភាពទាំងបួនខាងលើ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានរៀបចំ រចនាសម្ព័ន្ធដូចខាងក្រោម ៖

+សេចក្តីសម្រេច លេខ ០៦០/០៦ សសរ.កកចនយ ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមប្រតិបត្តិគម្រោងសិទ្ធិទទួលបានយុត្តិធម៌នៅកម្ពុជា

+សេចក្តីសម្រេចលេខ ០៦៨/០៦ សសរ.កកចនយ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមគម្រោងលើកកំពស់ការយល់ដឹងសិទ្ធិ ជាមូលដ្ឋាននៅកំរិតសហាគមន៍

+សេចក្តីសំរេចលេខ ៥៥ សសរ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦ ស្តីពីការបង្កើតក្រុមគម្រោង ធ្វើអោយប្រសើរឡើងរាជកិច្ច

+សេចក្តីសម្រេចលេខ ២២៣/០៦ តកក.សសរ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦ ស្តីពីការ បង្កើតក្រុមគម្រោងចងក្រង និងបោះពុម្ពសេចក្តីសម្រេចជាស្ថាពររបស់តុលាការ

- បានសហការជាមួយក្រុមបេសកកម្មស្វែងយល់របស់ AusAid រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃកម្មវិធី ជំនួយផ្នែកព្រហ្មទណ្ឌ និងយុត្តិធម៌នៅកម្ពុជា ជាបន្តសម្រាប់ឆ្នាំ ២០០៧-២០១៦ នៅកម្ពុជា នៅក្នុងនោះ មានគម្រោងពង្រឹងសមត្ថភាពអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌ផង ដែរ ។ ដូចគ្នានេះដែរ យើងបានទទួលជួបពិភាក្សា រៀបចំក្របខ័ណ្ឌសំរាប់ជំនួយជាបន្តជាមួយ DANIDA និង CIDA។

**គ. ការអនុវត្តសូចនាករ**

• សូចនាករសម្រាប់កំណែទម្រង់ច្បាប់ ឆ្នាំ ២០០៥ ផ្តោតជាសំខាន់លើការតាក់តែង និងការអនុម័តនូវ ច្បាប់ជាមូលដ្ឋាន ចំនួនប្រាំបីសម្រាប់យុត្តាធិការតុលាការរួមមាន ៖

- ក្រមរដ្ឋប្បវេណី
- ក្រមនីតិវិធីរដ្ឋប្បវេណី
- ក្រមព្រហ្មទណ្ឌ
- ក្រមនីតិវិធីព្រហ្មទណ្ឌ
- ច្បាប់ស្តីពីការរៀបចំតុលាការ
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម
- ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ច្បាប់ប្រឆាំងអំពើពុករលួយ ។

ក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងយុត្តិធម៌ ដោយមានកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ អង្គការ JICA និងជំនួយគាំទ្រដល់នីតិរដ្ឋរបស់បារាំង បានខិតខំបំពេញការងាររបស់ខ្លួនយ៉ាងស្វិតស្វាញ ដើម្បីឈានទៅសម្រេចសូចនាករប្រចាំឆ្នាំ ២០០៥ នេះ ។ ជាលទ្ធផល គឺសម្រេចបាននូវសេចក្តីព្រាងនៃក្រម និងច្បាប់ ជាមូលដ្ឋានសំខាន់ៗទាំងអស់ខាងលើ ។

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការបានយល់ច្បាស់ពីទំហំនៃការងារ និងពីបញ្ហាលំបាកផ្សេងៗ ដែលជាកត្តានាំអោយមានការយឺតយ៉ាវ មិនអាចសម្រេចបាននូវសូចនាករទាំងនោះទាំងស្រុងតាមកាលកំណត់ ហើយបានឯកភាពគ្នាបញ្ចូលការងារដែល នៅសេសសល់ពី ឆ្នាំ ២០០៥ មកជាសូចនាកររួមសម្រាប់ឆ្នាំ ២០០៦ទៀត។

• នៅឆមាសទី ១ ឆ្នាំ ២០០៦ នេះ ស្ថានភាពនៃការអនុវត្តសូចនាកររួមនោះមានដូចតទៅ ៖

- ក្រមនីតិវិធីរដ្ឋប្បវេណី ៖ ត្រូវបានរដ្ឋសភាអនុម័តរួច កាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ ហើយ បញ្ជូនទៅព្រឹទ្ធសភា ពិនិត្យ
- ក្រមនីតិវិធីព្រហ្មទណ្ឌ ៖ ត្រូវបានអន្តរក្រសួងពិនិត្យរួច ហើយក្រសួងយុត្តិធម៌បានរៀបចំបន្តនូវអន្តរ ប្បញ្ញត្តិ
- ក្រមរដ្ឋប្បវេណី ៖ សេចក្តីព្រាងកំពុងពិនិត្យនៅអន្តរក្រសួង
- ក្រមព្រហ្មទណ្ឌ ៖ សេចក្តីព្រាងបានឆ្លងកាត់ក្រុមប្រឹក្សាអ្នកច្បាប់ និងបញ្ជូនទៅអគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាលរួចហើយ រង់ចាំចូលអន្តរក្រសួង
- ច្បាប់លក្ខន្តិកៈចៅក្រម ៖ សេចក្តីព្រាងនៅទីស្តីការគណៈរដ្ឋមន្ត្រី រង់ចាំអន្តរក្រសួង

- ច្បាប់ស្តីពីការចាត់តាំងតុលាការ ៖ សេចក្តីព្រាងត្រូវបានពិនិត្យ និងកែសម្រួលដោយក្រសួងយុត្តិធម៌រួចហើយ
- សេចក្តីព្រាងច្បាប់វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ត្រូវបានពិនិត្យនៅក្រសួងយុត្តិធម៌ ប៉ុន្តែឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានស្នើសុំពិនិត្យឡើងវិញមុននឹង ផ្ញើទៅទីស្តីការគណៈរដ្ឋមន្ត្រី
- ច្បាប់ប្រឆាំងអំពើពុករលួយ ៖ សេចក្តីព្រាងត្រូវបានផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យដោយក្រុម ប្រឹក្សាអ្នកច្បាប់ និងបញ្ជូនទៅក្រសួងទំនាក់ទំនងជាមួយរដ្ឋ សភា ព្រឹទ្ធសភា និងអធិការកិច្ចវិញ ដើម្បីកែសំរួល ។

## II-ការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់ក្រសួងពាក់ព័ន្ធសំខាន់ៗ:

### ក-ក្រសួងយុត្តិធម៌

ក្រៅពីការតាក់តែងច្បាប់ជាមូលដ្ឋានសំខាន់ៗខាងលើ ក្រសួងយុត្តិធម៌ បានសម្រេចនូវសកម្មភាពសំខាន់ៗ ដូចខាងក្រោម:

- បានរៀបចំកសាងថ្មី នូវសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌ បានចប់សព្វគ្រប់ហើយ ដែលបច្ចុប្បន្នកំពុងពិនិត្យ និងកែសំរួលឡើងវិញ
- បានសហការជាមួយអង្គការ CCJAP អូស្ត្រាលី ពិនិត្យ និងកែសំរួលលើសៀវភៅក្បួននីតិវិធីតុលាការ និងរូបមន្តផ្នែកព្រហ្មទណ្ឌបានចប់ហើយ
- បានធ្វើការកែលំអក្រមសីលធម៌សំរាប់មេធាវី
- បានធ្វើវិធីសាស្រ្តរៀបចំតុលាការគំរូ
- បានធ្វើការរៀបចំសេចក្តីណែនាំ អំពីការគ្រប់គ្រងសំណុំរឿងក្តី និងតុលាការអោយស្របតាមបទបញ្ញត្តិ នៃក្រមនីតិវិធីច្បាប់អង្គការចាត់តាំងតុលាការ
- បានកសាងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាសាលា
- បានកសាងសេចក្តីព្រាងច្បាប់ស្តីពីរៀបចំ និងការប្រព្រឹត្តទៅនៃសារការី
- បានកសាងសេចក្តីព្រាងច្បាប់ភេរវកម្មថ្មី និងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រីរួចហើយ
- បានកសាងសេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធដំកល់
- បានកសាងសេចក្តីព្រាងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី
- បានសហការជាមួយអ្នកជំនាញការច្បាប់ជប៉ុន មានចៅក្រម ព្រះរាជអាជ្ញា មេធាវីជប៉ុន បើកសវនាការកាត់ក្តីគំរូ ដើម្បីបង្រៀនដល់សិស្សចៅក្រម និងមេធាវីខ្មែរនៅសាលាភូមិន្ទចៅក្រម ។

- រៀបចំកម្មវិធីសាកល្បង ដើម្បីបង្កើនការយល់ដឹងដល់សហគមន៍អំពីច្បាប់ និងលិខិតបទដ្ឋាន នានាពាក់ព័ន្ធដល់យេនឌ័រ និងពង្រីកក្រុមការងារយេនឌ័រ។
- បានផ្សព្វផ្សាយច្បាប់តាមវិទ្យុ ទូរទស្សន៍ សិក្ខាសាលា វេទិកាសាធារណៈ និងបោះពុម្ពកំរងច្បាប់ រៀបចំអត្ថបទច្បាប់ខ្លីៗ ងាយយល់ ងាយស្តាប់ និងមន្ត្រីរាជការក្នុងក្រសួង និងតាមសហគមន៍ ។
- បានតាមដានការប្រព្រឹត្តទៅរបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជីទាំងអស់ និងមានវិធាន ការតឹងរឹងបំផុតចំពោះការខុសឆ្គង ជាពិសេសលើក្រមសីលធម៌ ។
- បានរៀបចំកែសំរួលរចនាសម្ព័ន្ធការងារ ធ្វើអោយការអនុវត្តការងាររដ្ឋបាល និងតុលាការ ទទួលបានប្រសិទ្ធភាពខ្ពស់ និងមានការរីកចំរើននូវចំណាត់ការដោះស្រាយរឿងក្តីបានលឿន នៅតាមបណ្តា តុលាការ ខេត្ត ក្រុង ។
- បន្តជំរុញអោយការអនុវត្តសាលក្រម សាលដីកាស្ថាពរ និងសេចក្តីសម្រេចផ្សេងៗរបស់តុលាការ ។
- បន្តអោយព្រះរាជអាជ្ញាខេត្ត ក្រុង ចុះត្រួតពិនិត្យពន្ធនាគារ និងមន្ទីរឃុំឃាំងអោយបានត្រឹមត្រូវ តាមការកំណត់នៃច្បាប់ ។
- ចុះធ្វើអធិការកិច្ចនៅតាមតុលាការ និងអយ្យការខេត្ត ក្រុង ពង្រីកការគ្រប់គ្រងវិស័យយុត្តិធម៌អោយ មានប្រសិទ្ធភាពខ្ពស់ប្រកបដោយអភិបាលកិច្ចល្អ ។

**ខ-ក្រសួងមហាផ្ទៃ**

- បានសម្រេចលើសេចក្តីព្រាងដំបូងនៃច្បាប់ ស្តីពីការគ្រប់គ្រងខេត្ត ក្រុង ស្រុក ខណ្ឌ ផ្អែកតាមក្របខណ្ឌយុទ្ធសាស្ត្រស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ និងត្រៀមដាក់ជូនគណៈកម្មការអន្តរក្រសួងពិនិត្យ
- បានធ្វើសេចក្តីព្រាងច្បាប់ ស្តីពីសមាគមន៍ និងអង្គការក្រៅរដ្ឋាភិបាល
- ខិតខំសម្រេចការរៀបចំផែនការយុទ្ធសាស្ត្រ ស្តីពីការគ្រប់គ្រងពន្ធនាគារ ឆ្នាំ ២០០៦ ដល់ឆ្នាំ ២០១០ និងសេចក្តីព្រាងច្បាប់ ស្តីពីប្រព័ន្ធអប់រំកែប្រែនៅកម្ពុជា
- បានសហការជាមួយក្រសួងកិច្ចការនារី ដើម្បីព្រាងលិខិតបទដ្ឋានអនុវត្តច្បាប់ស្តីពីការទប់ស្កាត់ អំពីហិង្សា
- បានរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ និងដោះស្រាយទំនាស់នៅមូលដ្ឋាន
- ពង្រឹងការអនុវត្តច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន
- បានរៀបចំ និងពង្រឹងក្របខណ្ឌកងកំលាំងនគរបាលជាតិគ្រប់ផ្នែក គ្រប់ជាន់ថ្នាក់ និងពង្រឹងកង កំលាំងនគរបាលដោយវិជ្ជាជីវៈជំនាញ និងបច្ចេកទេសទំនើប

- បានពិនិត្យលទ្ធភាពបង្កើតមជ្ឈមណ្ឌលហ្វឹកហ្វឺនកងកម្លាំងប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន កិច្ចការ នេះក្រសួងមហាផ្ទៃ កំពុងពិចារណាទៅលើបទដ្ឋានច្បាប់នានា ដោយសហការជាមួយក្រសួងយុត្តិធម៌
- បាននិងកំពុងធ្វើសេចក្តីព្រាងច្បាប់ ស្តីពីបាតុកម្មដោយសន្តិវិធី ហើយបច្ចុប្បន្ននេះកំពុងតែដាក់ឆ្លងមតិ ប្រមូលផ្តុំមតិពីសមាជិកក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ ដើម្បីដាក់ក្នុងសិក្ខាសាលាមួយ ដែលនឹងត្រូវរៀបចំនាពេលខ្លីខាងមុខនេះ ដោយមានការឧបត្ថម្ភពីមជ្ឈមណ្ឌលអប់រំច្បាប់របស់សហគមន៍
- កំពុងពិចារណារៀបចំសេចក្តីព្រាងច្បាប់ ស្តីពីការគ្រប់គ្រងកាស៊ីណូ ជាមួយក្រសួងពាណិជ្ជកម្ម
- បានសហការធ្វើសេចក្តីព្រាងច្បាប់ ស្តីពីការបង្រ្កាបការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទបានចប់សព្វគ្រប់ដោយមានការចូលរួមពីក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី។

**ឥ-ក្រសួងពាណិជ្ជកម្ម**

**ច្បាប់ដែលអនុម័តរួច:**

- ច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- ច្បាប់ស្តីពីការគ្រប់គ្រងសុវត្ថិភាពផលិតផលទំនិញ និងសេវា
- ច្បាប់ស្តីពីម៉ាកពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ។

**ច្បាប់ដែលកំពុងស្ថិតនៅជាសេចក្តីព្រាង**

- ច្បាប់ស្តីពីប្រតិបត្តិការដែលមានកិច្ចធានា ៖ បច្ចុប្បន្ននេះកំពុងរង់ចាំការអនុម័តពីរដ្ឋសភា

  ច្បាប់ស្តីពីការក្ស័យធន ៖ បានឆ្លងកាត់ការប្រជុំអន្តរក្រសួងនៅទីស្តីការគណៈ-រដ្ឋមន្ត្រី ចំនួនពីរ លើករួចហើយ
- ច្បាប់ស្តីពីតុលាការពាណិជ្ជកម្ម
- ច្បាប់ស្តីពីការប្រកួតប្រជែងពាណិជ្ជកម្ម
- ច្បាប់ស្តីពីការសំគាល់លក្ខណៈភូមិសាស្ត្រទំនិញ
- ច្បាប់ស្តីពីការការពារការសំងាត់ពាណិជ្ជកម្ម និងព័ត៌មានសំងាត់ ។

**ទិសដៅនៃការកសាងច្បាប់ថ្មី**

- ច្បាប់ស្តីពីការផ្តល់សិទ្ធិអាជីវកម្ម

- ច្បាប់ស្តីពីការការពារសិទ្ធិអ្នកប្រើប្រាស់
- ច្បាប់ស្តីពីភ្នាក់ងារពាណិជ្ជកម្ម
- ច្បាប់ស្តីពីកិច្ចសន្យាពាណិជ្ជកម្ម ។

**ការបំពេញកាតព្វកិច្ចនានាឆ្លើយតបនឹងលក្ខខ័ណ្ឌតំរូវរបស់ WTO**

- បានធ្វើសមទិនបញ្ជីសកម្មភាពដែលក្រសួងពាណិជ្ជកម្ម និងក្រសួងពាក់ព័ន្ធនានាត្រូវធ្វើបន្តរៀងរាល់ ៦ ខែម្តងជាប្រចាំជាមួយអ្នក ជំនាញការ WTO។

**ការចុះទៅផ្សព្វផ្សាយច្បាប់តាមមូលដ្ឋាន និងសហគមន៍ ៖**

- ក្រសួងបានចុះទៅផ្សព្វផ្សាយច្បាប់ពាណិជ្ជកម្ម និងច្បាប់កម្មសិទ្ធិបញ្ញាបានចំនួន ១២លើក នៅខេត្ត ក្រុងចំនួន១២។

**ការបង្កើតយន្តការដោះស្រាយវិវាទក្រៅតុលាការ**

- មានគម្រោងបង្កើតមជ្ឈមណ្ឌលមជ្ឈត្តកម្មពាណិជ្ជកម្ម តាមការកំណត់របស់ច្បាប់មជ្ឈត្តការ ផ្នែកពាណិជ្ជកម្ម ដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មក្រៅតុលាការ ។ បច្ចុប្បន្ននេះ ក្រសួងកំពុងស្វះស្វែងរកជំនួយ ពីទីប្រឹក្សាអន្តរជាតិ ដើម្បីរៀបចំរចនាសម្ព័ន្ធ និងបទបញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធដូចជាអនុក្រឹត្យ ស្តីពីការអនុវត្តច្បាប់មជ្ឈត្តកម្មពាណិជ្ជកម្មជាដើម ក្នុងគោលដៅ ដំណើរការមជ្ឈមណ្ឌលនៅត្រីមាសទី៤ នៃឆ្នាំនេះ ។

**គម្រោងបង្កើតតុលាការពាណិជ្ជកម្ម**

- គម្រោងនេះនៅមានការខ្វែងគំនិតគ្នាមួយចំនួន អំពីបញ្ហាបច្ចេកទេស និងទស្សនៈវិស័យ ស្តីពីការបង្កើតតុលាការពាណិជ្ជកម្ម ដែលត្រូវស្ថិតនៅដោយឡែកពីប្រព័ន្ធតុលាការបច្ចុប្បន្ន។ ក្រសួងពាណិជ្ជកម្មមាន គម្រោងស្នើសុំអោយបង្កើតតុលាការពាណិជ្ជកម្មដោយឡែក ស្របតាមការសន្យានៅពេលចូលជាសមាជិករបស់អង្គការពាណិជ្ជកម្មពិភពលោក។ ចំណែកក្រសួងយុត្តិធម៌យល់ថា វិវាទពាណិជ្ជកម្មជាកិច្ចការបច្ចេកទេសដែល ត្រូវបង្កើតត្រឹមតែសភា (Chamber) មួយសំរាប់ដោះស្រាយកិច្ចការនេះ នៅក្រោមប្រព័ន្ធតុលាការបច្ចុប្បន្ន ។ កិច្ចការនេះស្ថិតនៅទ្រឹងនៅឡើយ ពុំទាន់មានការសម្រេចចិត្តជាក់លាក់ណាមួយទេ ។

## ឃ-រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

- បានជួបពិភាក្សាការងារជាមួយតំណាងស្ថានទូតបារាំងនៅកម្ពុជាក្នុងការបន្តជួយសាលាចៅ ក្រម និងសាលាក្រឡាបញ្ជី

- បានចូលរួមជាមួយគណៈប្រតិភូទៅទស្សនកិច្ចនៅប្រទេសបារាំង កាលពីដើមខែមិថុនា ឆ្នាំ២០០៦
- បានធ្វើសហប្រតិបត្តិការជាមួយ JICA លើការកែលំអការបណ្តុះបណ្តាលផ្នែករដ្ឋប្បវេណី និង ការសាងសង់អាគារថ្មីមួយខ្នង មានបីជាន់
- បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ EWMI, DANIDA និង CAFAF លើការងារបណ្តុះបណ្តាលបន្ត នៅសាលាចៅក្រម និងសាលាក្រឡាបញ្ជី
- បានធ្វើកិច្ចសហការប្រតិបត្តិការជាមួយ GIZ លើការលើកកំពស់សិទ្ធិនារី ផ្តល់អាហាររូបករណ៍ ដល់សិស្សនារីចំនួន ៣៥រូប ប្រឡងចូលសិស្សចៅក្រម ជំនាន់ទី២
- បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ UNICEF រៀបចំការបណ្តុះបណ្តាលគ្រូ និងសិស្សចៅក្រម ពាក់ព័ន្ធដល់បញ្ហាកុមារ
- បានធ្វើកិច្ចសហប្រតិបត្តិការជាមួយ CCJAP, ADB, ICO និង EU លើការបណ្តុះបណ្តាល ជំនាញផ្សេងៗមួយចំនួន ។

## III-ទិសដៅបន្តសម្រាប់ឆមាសទី ២ ឆ្នាំ ២០០៦៖

-បន្តគម្រោងការងារពីឆមាសទី ១ រួមមាន ៖

- បញ្ចប់ការស្ទង់មតិអំពីជំនួយផ្នែកច្បាប់ និងការរៀបចំកម្មវិធីសកម្មភាពសម្រាប់ការអនុវត្ត
- បញ្ចប់ការរៀបចំសេចក្តីព្រាងក្រមសីលធម៌សម្រាប់ចៅក្រម និងព្រះរាជអាជ្ញា
- បញ្ចប់ការរៀបចំគម្រោងលំអិត (ភរៀញចេត Profile)
- បញ្ចប់ការរៀបចំសៀវភៅណែនាំ (្យចេតៀរ Manual)
- រៀបចំប្រព័ន្ធសូចនាករ (ីនជិចាតៀរ System ) សំរាប់តានដានការអនុវត្តកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ទាំងមូល

-ជំរុញ និងតាមដានការអនុវត្តគម្រោងសិទ្ធិទទួលបានយុត្តិធម៌ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៦

-ទំនាក់ទំនង បំពាក់សំភារៈបរិក្ខាដល់ អ.គ.គ

-ជំរុញការអនុវត្តបញ្ហាប្រឈមដែលនៅសេសសល់

-បន្តសម្របសម្រួល និងពង្រឹងទំនាក់ទំនងជាមួយក្រសួង ស្ថាប័នអនុវត្ត

- បន្តការងារទំនាក់ទំនងរកដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្តគម្រោងដែលនៅសល់

-ពង្រឹងសមត្ថភាពមន្ត្រីរាជការក្នុងការរៀបចំ និងអនុវត្តគម្រោង នៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធ ។

IV-**សន្និដ្ឋាន ៖**

ចាប់តាំងពីរាជរដ្ឋាភិបាល បានអនុម័តកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥មក អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (អ.ស.អ) និងអង្គភាពគ្រប់គ្រងគម្រោង (អ.គ.គ) នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ (ក.ក.ច.ន.យ) បានខំប្រឹងប្រែងពន្យល់ និងផ្សព្វផ្សាយអោយប្រទេស និងអង្គការផ្តល់ជំនួយចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ ទៅតាម ក្របខ័ណ្ឌដែលរាជរដ្ឋាភិបាលបានកំណត់។ យើងបានកត់សំគាល់ឃើញថា USAid តាមរយៈវិទ្យាស្ថានគ្រប់គ្រងបស្ចិម-បូព៌ា (EWMI) និង PACT និងជាពិសេស UNDP បានលើកគម្រោងស្របតាមបញ្ជីគម្រោង (Project Catalogue) របស់ ក.ក.ច.ន.យ ហើយ AusAid ក៏បានឯកភាព នឹងរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ជំនួយ ជាបន្តរបស់ខ្លួន អោយស្របតាមបញ្ជីគម្រោងនេះដែរ ។

ចំពោះសកម្មភាពអាទិភាពរយៈពេលខ្លី ដែលមានចំនួនសរុប ៣៩សកម្មភាព យើងបាន និងកំពុងអនុវត្ត ស្ទើរតែទាំងអស់ នៅសល់តែសកម្មភាព ៤ ដែលពុំទាន់បានអនុវត្ត គឺការស្ទង់មតិលើកម្មវិធីបណ្តុះបណ្តាលបច្ចុប្បន្ន ពីសិទ្ធិមូលដ្ឋានសម្រាប់ទីភ្នាក់ងារអនុវតច្បាប់ ដើម្បីរកអោយឃើញចន្លោះប្រហោង និងកន្លែងដែលត្រូវកែលំអ (សកម្មភាពលេខ១.២.២) ការបង្កើតកម្មវិធី និងសម្ភារៈបណ្តុះបណ្តាល រួមទាំងការបង្កើតមុខវិជ្ជាសិទ្ធិមនុស្សនៅ កំរិតសកលវិទ្យាល័យ សម្រាប់កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តុះបណ្តាលបន្ត(សកម្មភាពលេខ១.២.៣) ការស្ទង់មតិលើយន្តការអនុវត្តច្បាប់នៃច្បាប់បច្ចុប្បន្ន ដើម្បីរកអោយឃើញចំណុចកែលំអ (សកម្មភាពលេខ ៥.១.១)និងការកសាងសមត្ថភាពចាំបាច់សម្រាប់ស្ថាប័ននីមួយៗ ដើម្បីបំពេញអាណត្តិរបស់ខ្លួន ដោយការអភិវឌ្ឍ គោលនយោបាយគ្រប់គ្រងធនធានមនុស្ស (សកម្មភាពលេខ ៧.១.១)។ សកម្មភាពដែលនៅសល់ទាំងនេះ អង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ និងអង្គភាពគ្រប់គ្រងគម្រោង បានទុកដូចជាគម្រោងថ្មី ដើម្បីទំនាក់ទំនងរក ដៃគូ ។

ចំពោះសកម្មភាពអាទិភាពរយៈពេលមធ្យមដែលមានចំនួនសរុប ៣៦ សកម្មភាព ដែលក្នុងនោះមានសកម្មភាពបន្តពីរយៈពេលខ្លីចំនួន ១២សកម្មភាព យើងបាន និងកំពុងអនុវត្ត ស្ទើរតែទាំងអស់ហើយដែរ នៅសល់ តែសកម្មភាព ៧ ដែលពុំទាន់បានអនុវត្ត គឺការបង្កើតការិយាល័យអំប៊ុសម៉ែន Ombudsman (សកម្មភាពលេខ ១.៦.១) ក្រមរដ្ឋបាល និងនីតិវិធីរដ្ឋបាល រួមទាំងវិធានច្បាប់សម្រាប់ប្តឹងតវ៉ា(ឧទ្ធរណ៍)នៅតុលាការ(សកម្មភាព លេខ២.១.១)

បទបញ្ញត្តិច្បាប់ ដើម្បីធានាឯករាជ្យភាពនៃសេវាអយ្យការ(សកម្មភាពលេខ២.១.៧) ការបង្កើតអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ(សកម្មភាពលេខ២.៣.៤) ការទទួលសាធារណជន (ការិយាល័យ) និងមុខងារព័ត៌មាននៅក្នុងតុលាការ(សកម្មភាពលេខ៣.៣.២) សម្ភារៈបរិក្ខាតុលាការគ្រប់គ្រាន់ ទាន់សម័យ រួមទាំងបរិក្ខាអាយធី (បច្ចេកវិទ្យាព័ត៌មាន ដែលពាក់ព័ន្ធ (សកម្មភាពលេខ៥.៤.៣) វិធានការបង្កើតតុលាការរដ្ឋបាល និងបែបបទតុលាការរដ្ឋបាល និងការបណ្តុះបណ្តាលផ្នែកច្បាប់រដ្ឋបាល (សកម្មភាពលេខ៥.៤.៥)។ ដូចគ្នានឹង សកម្មភាពអាទិភាពរយៈពេលខ្លីដែរ យើងបានទុកដូចជាគម្រោងថ្មី និងផ្សព្វផ្សាយរួចហើយដែរ ជូនសហគមន៍ផ្តល់ជំនួយ ។

ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នឹងខិតខំអោយអស់ពីលទ្ធភាព ក្នុងការពង្រឹងភាពជា ម្ចាស់ការរបស់ខ្លួន និងការស្វែងរកដៃគូជួយគាំទ្រ អនុវត្តសកម្មភាពរយៈពេលខ្លី និងរយៈពេលមធ្យមបន្តទៀត អោយបានជោគជ័យ ។

ដោយឡែកចំពោះដំណើររាំងស្ទះក្នុងការបង្កើតតុលាការឯកទេស ជាពិសេសតុលាការពាណិជ្ជកម្ម ដែលជាការតម្រូវរបស់អង្គការពាណិជ្ជកម្មពិភពលោក និងតុលាការរដ្ឋបាល ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និង ប្រព័ន្ធយុត្តិធម៌ នឹងលើកបញ្ហានេះជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីមានវិធានការដោះស្រាយ ។

រាជធានី ភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦

អ្នកធ្វើរបាយការណ៍

សួង លាងហៃ

បានឃើញ និងឯកភាព

ប្រធានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍

នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌

ស៊ុំ ម៉ានិត